# កម្ពុជសុរិយា

ទស្សនាវដ្ដី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

ឆ្នាំគំរប់ ១៣

ភាគទី ២០

ភ្នំពេញ

ការផ្សាយរបស់ព្រះរាជបណ្ណាល័យ

ព.ស. ២៤៨៤

គ.ស. ១៩៤១

ព្រះរាជបណ្ណាល័យកម្ពុជា

# KAMBUJASURIYÂ

# កម្ពុជសុរិយា

ជាទស្សនាវដ្ដីចេញផ្សាយពីព្រះរាជបណ្ណាល័យ មួយខែពីរក្បាល

ឆ្នាំគំរប់ ១៣

ភាគទី ២០

គណៈរដ្ឋមន្ត្រីនិងសម្ដេចសង្ឃនាយកទាំងពីរគណៈ
បានអនុញ្ញាតហើយ

ភ្នំពេញ
ការផ្សាយរបស់ព្រះរាជបណ្ណាល័យ
ព.ស. ២៤៨៤
គ.ស. ១៩៤១

# បញ្ជីរឿង


១— អារ្យធម៌របស់ឥណ្ឌា ក្នុងសម័យព្រះបាទចន្ទ្រគុប្តៈមៅរ្យៈ . . . . . . . . ៣

២— អំពីជម្ងឺឆ្លងចំពូកខ្វះ ជីវកកោមារភត្យៈ រៀបរៀង . . . . . . . . . . ៦

៣— វិធីធ្វើចំការច្បារដំណាំ- អ្នកស្រែម្នាក់រៀបរៀង . . . . . . . . . . . ១២

៤— ពង្សាវតារព្រះកែវមរកត ស្រង់យកអំពីគម្ពីរបាលី "រតនពិម្ពវង្ស" (តមកនឹងចប់). ១៨

៥— ពង្សាវតារក្រុងរោម ស្រង់យកអំពីគោលចារិកផ្សេងៗ ក្នុងពង្សាវតារលោក(តទៅ). ២១

៦— អំពីសេចក្តីចំរើននៃវិទ្យាសាស្ត្រ (តមកនឹងចប់) . . . . . . . . . . . ២៥


## រូបក្រៅរឿង


អង្គរធំ- ព្រះកេសព្រះពុទ្ធរូបខ្មែរ . . . . . . . . . . . . . . . . . ១

# TABLE DES MATIÈRES


Pages

1° Civilisation de l'Inde à l'époque de CHANDRAGUPTA MAURYA.. 3

2° Quelques maladies contagieuses, par JIVAKA KOMARABHATYA.. 6

3° La culture maraîchère et les jardins fruitiers, par un Néak-srè 12

4° Histoire de la statue du Bouddha d'émeraude. Extrait du texte Pali "RATANABIMBAVAMSA" (suite et fin)........... 18

5° Histoire de Rome Extrait de divers documents de l'histoire universelle (suite)........................................ 21

6° Le progrès de la science (suite et fin).................... 25


HORS TEXTES:


Angkor-Thom. — Tête d'une statue du Bouddha........... 1



អង្គរធំ — នេះគឺព្រះកេសព្រះពុទ្ធរូបសម័យអង្គរ ។

# អំពីចន្ទ្រគុប្តៈ ក្សត្រិយ៍មៅរ្យៈ
# ជាព្រះអយ្យកោនៃព្រះបាទអសោក

## ព. ស. ២២១ - ២៤១

ក្នុងសៀវភៅ ១ ដែលនិយាយពីពង្សាវតារប្រទេសឥណ្ឌានោះ យើងសូមស្រង់យកសេចក្តីមួយដែលនិយាយពីមហាក្សត្រិយ៍នៃប្រទេសឥណ្ឌាសម័យបុរាណ គឺក្នុងសម័យព្រះបាទចន្ទ្រគុប្តៈ ។ ក្នុងសម័យនោះ ប្រទេសឥណ្ឌាមានទីក្រុង ២០០០ ។ ក្រុងដែលចាស់ជាងគេហៅថា តក្កសិលា ។ តក្កសិលានេះជាក្រុង ១ ជាទីប្រជុំសិក្សាវិជ្ជាទាហាន ទឹងវិជ្ជាអ្នកប្រាជ្ញ ព្រោះជាទីក្រុងដ៏ស្តុកស្តម្ភ ទឹងមានមហាវិទ្យាល័យយ៉ាងល្បីល្បាញដែលមានក្នុងសម័យនោះ ។ មានពួកសិស្សមកនៅរៀនសូត្រក្នុងទីក្រុងនេះច្រើនណាស់ ពីព្រោះគេអាចនឹងរៀនវិជ្ជារចនាវិទ្យាសាស្ត្រនឹងអាចារ្យទិសាបាមោក្ខ ហើយនៅក្នុងមហាវិទ្យាល័យនេះមានសាលាបង្រៀនវិជ្ជាពេទ្យផង ដែលមានគ្រូឈ្មោះល្បីល្បាញណាស់ ។

បាដលីបុត្រ ជាទីក្រុងធំរបស់ព្រះបាទចន្ទ្រគុប្តៈ បណ្តោយចំនួន ១៥ គីឡូម៉ែត្រ ទទឹងចំនួន ៣ គីឡូម៉ែត្រ ។ ព្រះរាជវាំងរបស់ព្រះមហាក្សត្រិយ៍ធ្វើដោយឈើទាំងអស់ តែមានលំអជាទីចាប់ភ្នែកអ្នកផង ពីព្រោះ

សសរប្រាសាទសុទ្ធតែផែមាសស្រោបទឹងឆ្លាក់ក្បាច់ធ្វើជាគំនូររូបផ្សេងៗ ដូចជារូបសត្វនិងរូបដើមឈើជាដើម ។ ឯខាងក្នុងប្រាសាទមានគ្រឿងប្រដាប់ប្រដាយ៉ាងល្អថ្លៃថ្លានិងគ្រឿងពេជ្រទិលចិន្តាផ្សេងៗ ហើយមានផើងមាសជាច្រើន ដែលមានទំហំ១ម៉ែត្រ៨០សង់ទីម៉ែត្រ (វាស់កាត់មាត់ផើង) ។ ព្រះមហាក្សត្រិយ៍នេះមានព្រះជន្ម ២៤ វស្សា ទ្រង់ព្រះពស្ត្រកម្ពលយ៉ាងល្អប៉ាក់មាសព័ណ៌ក្រហមឈាមជ្រូក វេលាស្ដេចយាងនោះជួនកាលទ្រង់គង់លើព្រះសលៀងមាស ជួនកាលទ្រង់គង់លើព្រះទីនាំងគជេន្ទ្របង់គ្រឿងសព្វគ្រប់ ។ ក្នុងមួយថ្ងៃៗ ពេលវេលាសម្រាប់ព្រះមហាក្សត្រនេះបែកចេញជា ១៦ ភាគ ក្នុងមួយភាគៗមាន៩០ មិនុតដូច្នេះគឺក្នុងភាគដំបូងទ្រង់ធ្វើសមាធិភាវនា . ភាគទី ២ ទ្រង់ត្រួតពិនិត្យសេចក្ដីរាយការរបស់ពួកខ្ញុំរាជការនិងទ្រង់មានព្រះឱង្ការបង្គាប់ ភាគទី ៣ ស្ដេចចេញទៅទទួលភ្ញៀវផ្ទាល់ព្រះអង្គ(មិនមែនជាការរាជការ) ភាគទី ៤ ទ្រង់ពិនិត្យឃ្លាំងប្រាក់និងប្រាក់ចំណាយចំណូលក្នុងស្រុក ភាគទី ៥ ទ្រង់ទទួលបណ្ដឹងរបស់បណ្ដារាស្ត្រនិងទ្រង់វិនិច្ឆ័យក្ដី ភាគទី ៦ ទ្រង់ស្រង់ព្រះឧទកៈនិងទ្រង់សោយព្រះក្រយាស្ងាយ ភាគទី ៧ ទ្រង់ទទួលពន្ធដារការសុំនិងទ្រង់តាំងមន្ត្រី ភាគទី ៨ ទ្រង់ពិនិត្យមើលសេចក្ដីរាយការរបស់ពួកចារបុរសនិងពួកខ្ញុំរាជការខាងក្នុងព្រះរាជវាំង ភាគទី ៩ ទ្រង់សម្រាកព្រះអង្គនិងទ្រង់សូត្រធម៌ ភាគទី ១០ និងភាគទី ១១ ទ្រង់សម្រេចកិច្ច

ការខាងកងការទាហាន ភាគទី ១២ ទ្រង់ពិនិត្យកិច្ចការសម្ងាត់ ភាគទី ១៣ ទ្រង់ស្រង់ព្រះឧទកៈ នឹងទ្រង់សម្រាកព្រះអង្គក្នុងវេលាល្ងាច ភាគទី ១៤-១៥-១៦ ទ្រង់ផ្ទុំ ។

ឯកងទ័ពរបស់ព្រះបាទចន្ទ្រគុប្តៈមានពលដំរី ៩.០០០ មានទាហានសេះ ៣០.០០០ មានទាហានថ្មើរជើង ៦០០.០០០ នាក់ ។ ក្នុងពេលដែលមានចម្បាំង ពួកអ្នកស្រែនឹងពួកព្រាហ្មណ៍មិនបាច់ធ្វើកងការទាហានទេ ពួកអ្នកស្រែចំការគិតតែធ្វើស្រែភ្ជួរដីរបស់ខ្លួនតែមួយមុខមិនបាច់គិតគួរពីចម្បាំងកាំងផល់ទេ ។ បណ្ដាផ្ទះដែលមានលេងល្បែង រាជការហូតពន្ធ ៥% ពីផលប្រយោជន៍ល្បែងដាក់យ៉ាំង ។ រដ្ឋបាលបានចាត់ការយកពន្ធអំពិលដាច់មុខជារបស់រដ្ឋបាល ព្រមទាំងសេះនឹងដំរីផង ។ នៅតាមផ្លូវធំៗ មានសសរខឿននឹងសិលាចារិកពន្យល់ប្រាប់ទីកន្លែងផ្សេងៗ នឹងរយៈផ្លូវឆ្ងាយជិតផង ។ ក្នុងកំណាត់រយៈផ្លូវនីមួយៗ មានដាំដើមឈើ ជីកអណ្ដូង មានភោជនស្ថាន មានប៉ុស្តិ៍ប៉ូលិស ។

អំពីជម្ងឺឆ្ងង៍កំពូការ ១៤:

# កាមរោគជាជម្ងឺឆ្លង ១:

កាមរោគជាឈ្មោះរួមនៃរោគស្រី គឺស្វាយ, ប្រមេះ, ទិមឡា, សុទ្ធតែជាហេតុបណ្ដាលឲ្យកើតរោគឡើងដោយឡែកៗពីគ្នា មេរោគអស់នេះមាននៅតាមដំបៅសើស្បែកទីកន្លែងណាមួយរបស់អ្នកជម្ងឺ នៅក្នុងដំបៅតាមសាច់ខ្ចី តាមផ្លូវបស្សាវៈ រន្ធយោនី មាត់ រីមស្បូនទីកន្លែងក៏សឹងមាន នៅទីអវយវៈតពូជរបស់អ្នកជម្ងឺក៏មាន ។

## ហេតុដែលឆ្លង:

១– ដោយហេតុបានជួបប្រសព្វនឹងមេរោគ ដូចការរួមប្រវេណីច្របូកច្របល់គ្នា ឬទៅរួមប្រវេណីនឹងស្ត្រីផ្កាមាសជាដើមហេតុ ។

២– ដោយការប្រើប្រាស់គ្រឿងសំលៀកបំពាក់ ដែលមានមេរោគនេះរួមជាមួយគ្នា ដូចក្រមាជូតទឹក ឬប្រើសំពត់ជូតរួមចូលគ្នាជាដើម ។

៣– ចំពោះស៊ីហ្វីលិសនោះ ស្ត្រីដែលកើតរោគនេះអាចចម្លងមេរោគទៅឲ្យកូនដែលនៅក្នុងគភ៌ក៏បាន នេះជាហេតុ ១ ដែលធ្វើឲ្យទារកស្លាប់ក្នុងគភ៌មុនប្រសូត ។

៤– ស្ត្រីដែលកើតប្រមេះ អាចចម្លងរោគនេះចូលក្នុងទារកក្នុងខណៈប្រសូតក៏សឹងមាន ។

## វិធីបង្ការរោគៈ

១ – ត្រូវលើកលែងរួមប្រវេណីនឹងអ្នកដែលមានកាមរោគ ឬស្ត្រីផ្កាមាសឲ្យស្រឡះ ។

២ – ប្រសិនបើដឹងខ្លួនថាមានកាមរោគហើយ គោងប្រញាប់រក្សាឲ្យស្រះជាស្រឡះ ព្រោះការទុកយោលយូរ អាចធ្វើឲ្យអវយវៈផ្សេងៗក្នុងកាយកើតរោគឡើង នាំឲ្យលំបាកវេទនាអស់កំឡាំងឬទៅជាខូចចរិតខូចខួរក្បាល នឹងរាលដាលទៅដល់កូន ឬធ្វើឲ្យរលូតកូនក៏សឹងមានច្រើន ។ អ្នកដែលស្លាប់ដោយដាច់សរសៃឈាមក្នុងខួរក្បាលនោះច្រើនតែកើតមកពីជម្ងឺស៊ីហ្វីលីស ដែលធ្វើឲ្យប្រសាទនេះរឹងស្រួយបែកដាច់ដោយងាយ ។

៣ – រោគប្រមេះជារោគដែលធ្វើឲ្យស្ត្រីរងទុក្ខវេទនាជាច្រើន លុះរោគនេះរាលដាលទៅដល់ស្បូននឹងអវយវៈជិតខាង មុខជាត្រូវវះកាត់ត្រង់ថ្លាសពោះដើម្បីរក្សាព្យាបាល ។ បើកើតដល់បុរសច្រើនតែធ្វើឲ្យស្អុក (ឥតកូន) នឹងរីងរៃរងទុក្ខវេទនាអស់កាលយូរ ។

៤ – ការអប់រំប្រជាជនឲ្យមានចំណេះវិជ្ជានឹងសីលធម៌ល្អនឹងកំចាត់ឲ្យបាត់រោគនេះស្រឡះទៅ ទើបអាចបន្ថយចំនួនជម្ងឺកាមរោគនេះឲ្យតិចចុះទៅបាន ។

## អំពីរបួសក្លាយ

មេរោគរបួសក្លាយ ច្រើនមាននៅទឹងសាច់សេះ តាមទីដីដាំដំណាំផ្សេងៗទឹងសម្រាមផង់ល្អងធូលី ហើយឆ្លងទៅកាន់មនុស្សដោយមេជម្ងឺចូលទៅតាមមុខរបួស ។ របួសដែលកើតនៅជើងច្រើនតែរបួសដែលមុតទឹងវត្ថុស្រួចហើយស្មោកគ្រោកផង មានអាចម៍ដីឬកំទេចឈើជាប់នៅទឹងកន្លែងដែលមុតនោះផង ហើយជារបួសមានខ្នាតតូចតែជ្រៅ ទើបធ្វើឲ្យកើតទៅជារបួសក្លាយ កាលដកវត្ថុដែលមុតនោះចេញហើយ មុខរបួសក៏បិទជិត ។

មាន់ចឹក ឆ្មាក្រចៅ, ក៏អាចធ្វើឲ្យទៅជារបួសក្លាយបានដែរ ។

ការវះកាត់ ការសម្រាលកូន ទឹងការចាក់ថ្នាំ បើមិនប្រយ័ត្នសំអាតឲ្យល្អ ក៏អាចធ្វើឲ្យកើតទៅជារបួសក្លាយបានដែរ ។

## វិធីបង្ការរោគនេះ

ប្រសិនបើមានរបួសតាមសាច់ស្បែក ដោយត្រូវឈើស្មោកគ្រោក បុកមុត ឬមុតទឹងដែកគោល ឬក៏មុខរបួសមិនស្អាតប្រឡាក់ដី ត្រូវលាងរបួសទឹងចាក់សេរ៉ូមបង្ការរបួសក្លាយផង ។

## អំពីការប្រយ័ត្នក្នុងការបរិភោគអាហារ

យើងច្រើនតែយល់ថា ការស្លាក់ឆ្អឹងឬឈ្លក់ទឹកនេះជារបស់ធម្មតាមិនជាការសំខាន់ប៉ុន្មានទេ ដោយយល់ថា មនុស្សយើងស្ទើរតែគ្រប់គ្នា

ធ្លាប់ស្លាក់ឆ្អឹងមកហើយ ។ តែគេពុំយល់ថា នោះជាគ្រោះគ្រោះល្អ ព្រោះឆ្អឹងដែលស្លាក់នោះមានខ្នាតតូចទើបរបូតចេញមកបាន មិនសូវមានទុក្ខវេទនាប៉ុន្មាន ប៉ុន្តែបើយើងល្បងនឹកដល់អ្នកដែលស្លាក់ឆ្អឹងធំៗ ជាប់ឆ្អឹងនៅក្នុងបំពង់ក នោះនឹងឃើញថាមុខគួរស្រប់ស្រួលយ៉ាងណាទៅ ។ អ្នកដែលធ្វើការនៅមន្ទីរពេទ្យតែងបានជួបប្រទះនឹងអ្នកដែលមានគ្រោះថ្នាក់តាមទំនងនេះជាញឹកញាប់បំផុត មានអ្នកជម្ងឺខ្លះដល់នូវមរណភាពដោយហេតុនេះក៏មាន ហេតុនេះសូមពន្យល់អំពីវិធីការពារទុកជាមុនក្នុងទីនេះ ជាផ្លូវជួយដាស់តឿនក្រើនរំលឹកដល់គ្នីគ្នាក្នុងខណៈបរិភោគអាហារ ។

## សេចក្ដីធ្វេសប្រហែស

គឺ:

១— សេចក្ដីធ្វេសប្រហែសក្នុងការរៀបចំធ្វើអាហារ

២— សេចក្ដីធ្វេសប្រហែសក្នុងការស៊ីនិងការផឹក

៣— សេចក្ដីធ្វេសប្រហែសក្នុងការបៀមវត្ថុអ្វីមួយនៅក្នុងមាត់

៤— ការធ្វេសប្រហែសរបស់ម្ដាយឪពុកនិងគិលៀង

៥— ការធ្វេសប្រហែសក្នុងការលេង ។

## ១— សេចក្ដីធ្វេសប្រហែសក្នុងការរៀបចំធ្វើអាហារៈ

អ្នកដែលមានមុខក្រសួងខាងចំអិនអាហារភោជនខ្លះ ច្រើនតែធ្វេសប្រហែសឲ្យមានឆ្អឹងតូចៗលាយឡំនឹងអាហារ ឬជួនកាលកំទេចចាន សរ-

ខ្សែលួស, កន្ទាស់, សក់ ៗ ល ៗ លាយឡំនៅក្នុងអាហារភោជន ហេតុនេះ អ្នកដែលមាននាទីចំអិនអាហារ គេនឹងតែប្រយ័ត្នវត្ថុអស់នេះ កុំឲ្យមានជាប់នៅក្នុងចំណីអាហារ ហើយគេនឹងគិតដល់អ្នកដែលបរិភោគផង ៗ

## ២– សេចក្តីធ្វេសប្រហែសក្នុងការស៊ីនិងផឹកៈ

កុំយល់ថាការស៊ីនឹងការផឹកនេះជារបស់ងាយស្រួល ព្រោះមានជួនកាលអាចឲ្យទោសដល់យើង ដូចជាមនុស្សល្មោភស៊ី ច្រើនតែកាយញាត់ៗ ស្ទើរតែទំពាមិនទាន់ យើងអាចសង្កេតឃើញបានដោយងាយ មនុស្សបែបនេះច្រើនតែអួលបាយសំឡរឿយៗ ជួនកាលស្លាក់ឆ្អឹងក៏មាន ដូចមានយាយចាស់ម្នាក់ បរិភោគនំបញ្ចុកលេបចូលទៅក្នុងបំពង់កព្រមទាំងទឹកសម្លដោយឥតទំពា ហើយដឹងខ្លួនថាហាក់ដូចជាមានអ្វីធ្លាក់ទៅក្នុងបំពង់ក ហើយយាយនេះគាត់មិនមានធ្មេញផង កាលនាំខ្លួនទៅឆ្លុះមើល ស្រាប់តែឃើញមានម្ជុល ១ ធ្លាក់ទៅក្នុងក្រពះអាហារ តែជួនជាគ្រោះល្អ ដល់ពេលបន្ទោបង់ឧច្ចារៈ ម្ជុលក៏ជ្រុះមកដោយស្រួល ៗ មានតួយ៉ាង ១ ទៀតថាហុតទឹកសម្លដោយទាំងផ្លែសន្ទូចធ្លាក់ចូលទៅក្នុងបំ-ពង់ក នេះមកពីការធ្វេសប្រហែសរបស់អ្នកបរិភោគអាហារ ៗ មនុស្សចាស់ខ្លះខ្លួនមិនមានធ្មេញទេ តែបរិភោគគ្រឿងស្វិតដូចសាច់គោជាដើម ៗ មានតួយ៉ាងជាច្រើន មនុស្សចាស់ស៊ីសាច់ទាំងដុំឥតទំពា ហើយដុំសាច់នៅជាប់ណែនក្នុងក្នុងបំពង់ក លេបបញ្ចូលក៏នៅតែមិនចូល គេនាំខ្លួនទៅមន្ទីរពេទ្យ ៗ

ការផឹក — មានអ្នកខ្លះឃើញតែទឹក ក៏បេះតែផឹកក្អឹកៗ ទៅមិនប្រយ័ត្ន ចួនកាលមានហេតុនាំឲ្យមានគ្រោះថ្នាក់ក៏សឹងមាន ដូចអ្នកខ្លះដែលចូលចិត្តផឹកទឹកក្រូចច្របាច់ មានចួនកាលផឹកដោយទាំងគ្រាប់ក្រូចក៏មាន មានអ្នកខ្លះផឹកប្រញាប់ពេក ទៅជាឈ្លក់ស្រឡកក៏មាន ហេតុនេះអ្នកធ្វើតោងតែប្រុងប្រយ័ត្ន អ្នកផឹកក៏តោងតែពិនិត្យមុននឹងផឹកដែរ ។ មានអ្នកខ្លះខ្លួនដាក់ធ្មេញ វេលាលេបថ្នាំគ្រាប់ជាមួយនឹងទឹក មិនបានជាប្រុងប្រយ័ត្នឲ្យល្អ ធ្មេញដែលដាក់ក៏របូតជ្រុះចុះចូលទៅជាមួយនឹងថ្នាំគ្រាប់ជាប់នៅក្នុងបំពង់កក៏មាន ។

ហេតុនេះ ទើបត្រូវតែមិនមានសេចក្ដីប្រមាទក្នុងការផឹកនឹងការស៊ី មានទំនងដូចជាយើងដើរចូលទៅក្នុងព្រៃដែលមានបន្លា យើងត្រូវតែដើរយ៉ាងសន្សឹមៗ មិនរួសរាន់ មិនឲ្យបន្លាមុតជើងយ៉ាងណា ការស៊ីនឹងការផឹកក៏ត្រូវតែប្រុងប្រយ័ត្នដូច្នោះដែរ ។

(នៅមានត)

# វិធីធ្វើចំការច្បារដំណាំ

ការធ្វើដំណាំនៅស្រុកខ្មែរយើងនេះមាន ២ យ៉ាង គឺចំការបន្លែម្យ៉ាង ចំការស៊ីផ្លែម្យ៉ាង ។

ឯចំការបន្លែ ខ្មែរក្តី ចិនក្តី ច្រើននិយមធ្វើក្នុងដីដែលមានទឹកប្រើប្រាស់បរិបូណ៌ ដូចនៅតាមមាត់ទន្លេមេគង្គនិងមាត់ទន្លេសាប ក្រៅពីនេះមានធ្វើចំការបន្លែខ្លះតាមជាយក្រុង ដូចជាចំការចិននៅខាងលិចផ្សារថ្មីក្រុងភ្នំពេញជាដើម ។ ចំការបន្លែដែលធ្វើជិតក្រុងនេះស្រួលលក់ដូរណាស់ គឺបេះពេលព្រឹកយកទៅលក់ពេលល្ងាចបាន ហើយលក់ដាច់ជានិច្ចឥតមានសល់ទាំងបានថ្លៃផង តែចំការដែលនៅឆ្ងាយពីផ្លូវទឹកនេះគោងតែទៀយបន្តិចទើបធ្វើបានផលល្អ គឺគោងដីកអណ្តូង, ស្រះ, ជាដើម សម្រាប់ប្រើស្រោចដំណាំក្នុងរដូវខែប្រាំង ។ តែចំការដែលមាននៅក្បែរក្រុងក្បែរទីផ្សារនេះ មិនសូវឃើញមានខ្មែរធ្វើទេ ទុកជាមានធ្វើខ្លះក៏បន្តិចបន្តួច ។ ឯពួកចិនវិញគេចាប់ធ្វើជារបរចិញ្ចឹមជីវិតមិនបាច់ធ្វើរបរដទៃទេ ដោយពួកនេះមានសេចក្តីខ្នះខ្នែងមិនទម្រន់ដូចខ្មែរយើង ទើបគេអាចចិញ្ចឹមពោះរស់ជីវិតបានដោយការធ្វើចំការបន្លែក្នុងទីដីត្រឹម ១ ឡូ ឬ ២ ឡូប៉ុណ្ណោះ ។

តាមដោយពិត ការធ្វើចំការនេះ មិនមែនកំណត់ថាជាតិចិនទើបធ្វើបានផលចំរើនល្អដូច្នេះឡើយ ជាតិខ្មែរក៏អាចធ្វើចំការដាំបន្លែផ្សេងៗ

បានដែរ តែតោងមានសេចក្ដីអត់ធន់នឹងព្យាយាមឲ្យម៉ឺងម៉ាត់ឡើង ហើយបេះដឹងរបៀបធ្វើចំការខ្លះប៉ុណ្ណោះ ក៏ល្មមនឹងធ្វើការនេះបានសម្រេចមិនខាន ។ តាមធម្មតា បន្លែផ្សេងៗជាដំណាំគោកត្រូវការទឹកតិចក៏ពិតមែន តែត្រូវការទឹកជារឿយៗ ។ ហេតុនេះ ការធ្វើចំការបន្លែតោងតែនៅជិតអណ្ដូង, ជិតស្រះ ឬជិតផ្លូវទឹក ដើម្បីស្រួលដល់ការស្រោចទឹកដំណាំថែមទាំងបន្លែផ្សេងៗក៏ច្រើនដុះលូតលាស់ល្អក្នុងរដូវរងានឹងរដូវប្រាំង បើក្នុងរដូវទាំងពីរនេះមិនមានទឹកស្រោចគ្រប់គ្រាន់ទេ ការធ្វើចំការបន្លែក៏មិនបានផលចំរើនល្អដែរ ។ ក្រៅពីទឹក តោងបេះវិធីត្រៀមដីដាក់ជី, ដាំនឹងការថែរក្សា តែថាការដាំបន្លែមានអន្ដរាយធំនៅត្រង់សត្រូវរបស់ដំណាំតោងតែប្រយ័ត្ននឹងពិនិត្យត្រួតត្រាកំចាត់ចេញ ។ សត្រូវដំបូងរបស់បន្លែគឺស្រមោច ដ្បិតគ្រាប់បន្លែច្រើនតែតូចៗទើបស្រមោចនាំគ្នាជញ្ជូនយកទៅស៊ីបានដោយងាយៗ ។ មួយវិញទៀត គ្រាប់បន្លែនេះបើកប់ទៅក្នុងដីជ្រៅពេកក៏ច្រើនតែរលួយស្អុយខូចអស់ បើដាំរាក់ពេកក៏មិនសូវដុះល្អព្រោះគ្រាប់បន្លែត្រូវការកំដៅនិងដីសើមនិងអាកាសតែល្មមសមគួរ កាលបើដុះឡើងហើយ តោងមានពន្លឺថ្ងៃកំដៅថ្ងៃឲ្យបានច្រើនផងទើបដុះល្អ ៗ ឯការចៀសវាងឲ្យផុតពីស្រមោច តោងធ្វើកន្លែងបណ្ដុះគ្រាប់បន្លែដោយឡែក ដើម្បីបណ្ដុះគ្រាប់បន្លែឲ្យដុះឡើងហើយសិមដកយកទៅផ្សាំ លុះ

មានសន្ទឹក ៦-៨ ហើយសឹមដកយកទៅដាំក្នុងចំការគេទៅ កាលបើដាំហើយគេនឹងឧស្សាហ៍ស្រោចទឹក, ជ្រួយដី, ដម្រះស្មៅ, ដាក់ជី បើមានដង្កូវឬសត្វល្អិតមកបៀតបៀនយាយី ត្រូវរកឧបាយកំចាត់ចេញតាំងអំពីដំបូង កាលបើធ្វើដូច្នេះ ការដាំបន្លែទើបបានផលចំរើនល្អដូចបំណងមិនខាន ។

ឯបន្លែដែលយើងត្រូវការដាំក្នុងចំការនេះមានច្រើនយ៉ាងណាស់ តែយើងត្រូវរើសដាំតែបន្លែតាមសេចក្ដីត្រូវការរបស់ផ្សារនឹងដាំឲ្យត្រូវតាមរដូវកាលផង ដូចជាបន្លែប្រើស្លឹក, បន្លែប្រើមើម, បន្លែប្រើផ្លែជាដើម គេនឹងរើសឲ្យត្រូវនឹងសេចក្ដីត្រូវការរបស់ផ្សារនឹងតាមរដូវកាលរបស់បន្លែនោះៗផង ។

ការធ្វើសួនផ្កា ក៏មានទំនងដូចការធ្វើចំការដាំបន្លែដែរ តែខសំខាន់អ្នកធ្វើសួនគេនឹងចេះដឹងរបៀបដាំនឹងបំណងរបស់ផ្សារ កាលបើឃើញថាផ្កាអ្វីលក់ដាច់ មានមនុស្សត្រូវការច្រើន គេនឹងយើងស្វែងរកពូជផ្កានោះមកដាំ ទើបបានផលចំរើនតាមបំណង ។ ពិតមែនតែដើមផ្កាមិនសម្រាប់ធ្វើជាអាហាររបស់មនុស្សយើងដូចជាបន្លែ តែមនុស្សយើងត្រូវការផ្កាជាចំនួនច្រើនសម្រាប់ប្រដាប់តាក់តែងក្នុងពិធីបុណ្យផ្សេងៗ បុណ្យខ្មោចក្ដី បុណ្យជាមង្គលផ្សេងៗក្ដី សឹងត្រូវការផ្កាផ្សេងៗសម្រាប់ប្រដាប់ជាគ្រឿង

លំអ ហេតុនេះបានជានៅទីជិតក្រុងឬជិតជំរុំជនមានអ្នករកស៊ីដាំផ្កាលក់ក៏មាន ។

ការធ្វើចំការដើមឈើស៊ីផ្លែក្នុងស្រុកយើងនេះមានគេនិយមដាំទូទៅ តែដែលគេស៊ីទីចំការនេះដោយឡែកមិនបាច់ពឹងរបរដទៃទៀតជាគ្រឿងចិញ្ចឹមជីវិតក៏មាន ដូចមាននៅតាមសងខាងដងទន្លេមេគង្គ, ដៃទន្លេសាប ទឹងស្ទឹងព្រែកដទៃទៀតក៏មានខ្លះ ដែលដាំបន្តិចបន្តួចនៅក្នុងភូមិ ដូចជា ដូង, ស្វា, ស្វាយ, ខ្នុរ, មៀន, ក្រូច, ចេក ជាដើម សឹងមានគ្រប់ៗភូមិក្នុងស្រុកខ្មែរ ប៉ុន្តែវិធីដាំមិនសូវមានរបៀបរៀបរយល្អទេ ដោយហេតុគ្រាន់តែមានទីដីទំនេរទើងនៅជិតទឹកក៏ចេះតែដាំច្របូកច្របល់គ្នា ហើយច្រើនតែដាំជិតគ្នាពេកផង ទាំងមិនចេះវិធីថែទាំយ៉ាងល្អទេ គ្រាន់តែស្រោចទឹកទឹងជម្រះស្មៅទុកជាស្រេច ។

ការដាំឈើស៊ីផ្លែនៅស្រុកខ្មែរយើងនេះ ដែលនិយមធ្វើរៀងៗមកនេះមិនសូវមានផលចំរើនពេញលេញល្អ វិធីកែខៃឲ្យបានល្អឡើងនោះគួរធ្វើដូច្នេះ:

១– ការដាំដើមឈើស៊ីផ្លែ – មានវិធីដែលគួរប្រតិបត្តិជាច្រើនប្រការដូចជា:

ក) ការកំណត់របៀបដាំ – បើជាទីទំនាបមានទឹកជោរនាចឬទឹកលិចដល់គួរលើកដីធ្វើជាថ្នាលៗ ត្រង់ខ្នងថ្នាលយ៉ាងតូចត្រឹម ៣ ព្យាម កាល

បើដាំដើមឈើនៅកណ្ដាលថ្នាលហើយ ដើមឈើមានរយៈឃ្លាតពីគ្នាល្មម តាមសេចក្ដីត្រូវការរបស់ដើមឈើ បើដាំទីសួនមិនបាច់លើករងថ្នាលទេ កាលបើរៀបចំដីស្រេចសព្វគ្រប់ហើយក៏កំណត់រយៈដាំតែម្ដង ។

២– ការកំណត់រយៈដាំ បើដាំសួនដីករងលើកថ្នាលគួរដីករណ្ដៅ ដាំឲ្យចំកណ្ដាលថ្នាល បើដាំទីសួនមិនបាច់ដីកដីលើកថ្នាលទេ ត្រូវប្រើខ្សែរក់អំពីជ្រុងសួនទាំងខាងទទឹងទាំងខាងបណ្ដោយឲ្យមានជ្រុងជ្រោយល្អ ហើយដោតដាំបង្គោលឲ្យមានរយៈល្មមនឹងសេចក្ដីត្រូវការរបស់ដើមឈើនោះៗ ។

៣– ការដាំនេះ គួរដាំឲ្យមានរយៈឃ្លាតពីគ្នាកុំឲ្យញឹកពេក ដើមឈើមិនដុះលូតលាស់ល្អទាំងមិនមានផ្លែផ្កាតាមបំណងរបស់យើង ដោយហេតុដើមឈើដណ្ដើមពន្លឺថ្ងៃ អាកាសនិងអាហារចំណីគ្នា បើដាំឃ្លាតពីគ្នាពេកទាំងខូចខាតទីដីឥតប្រយោជន៍ ។ ការកំណត់រយៈដាំដើមឈើនេះ គួរកំណត់យកចុងមែកធាងជាប្រមាណ គឺកាលបើដើមឈើធំចំរើនពេញលេញហើយ ចុងមែកធាងបែកចេញទៅក្រៅដើមត្រឹមណា ត្រូវកំណត់យក ២ ភាគរបស់មែកធាង ដូចជាដូងដែលដុះចំរើនពេញលេញ បណ្ដោយធាងដូងប្រហែលជាង ២ ព្យាម យើងត្រូវដាំឲ្យមានរណ្ដៅឃ្លាតពីគ្នារវាង ៤ ព្យាមជាដើម ។

៤- ការរើសពូជដំណាំសម្រាប់ដាំ- គួររើសដាំតែពូជដំណាំដែលត្រូវនឹងទឹកដីអាកាសហើយមានផលចំរើនល្អមានដម្លៃធំ បើឃើញថាពូជដំណាំបែបណា ត្រូវនឹងទឹកដីអាកាសកន្លែងចំការរបស់ខ្លួនហើយ ត្រូវស្វែងរកមកដាំឲ្យបានច្រើន  ការដាំដំណាំបន្តិចបន្តួចដែលមិនបានដឹងជាមានផលចំរើនឬទេ  នោះត្រូវទុកស្ទះសិនកុំដាំ  ព្រោះអាចនាំឲ្យខូចកំឡាំង-ឥតប្រយោជន៍ ។

(នៅមានត)

# ប្រវត្តិព្រះកែវមរកត ៨

ស្រង់យកអំពីគម្ពីររតនពិម្ពវង្ស (តមកនឹងចប់)

តមកស្ដេចស្រុកកំពែងពេជ្រមានព្រះរាជបុត្រច្បង ១ អង្គ ទ្រង់តាំងឲ្យទៅគ្រងស្រុកលៈវ៉ៅ លុះរាជកុមារនេះបានគ្រងស្រុកលៈវ៉ៅ ក៏នឹករឭកដល់ព្រះកែវ ទើបទូលសុំព្រះកែវនាំទៅស្រុកលៈវ៉ៅ ហើយធ្វើបុណ្យសម្ពោធ និងប្រតិបត្តិថែរក្សាជាវេលា ១ ឆ្នាំ ៩ ខែ ទើបនាំមកទុកឯស្រុកកំពែងពេជ្រវិញ ។

គ្រានោះ មានស្ដេច ១ អង្គព្រះនាមព្រហ្ម គ្រងរាជសម្បត្តិក្នុងស្រុកជៀងរ៉ាយ ជាមិត្រមេត្រីនឹងស្ដេចកំពែងពេជ្រ ក៏ទ្រង់មានព្រះរាជបំណងចង់បានព្រះកែវមកទុកក្នុងស្រុករបស់ទ្រង់ ដើម្បីនឹងធ្វើសក្ការបូជាដែរ ទើបទ្រង់នាំសេនាមាត្យរាជបរិពារចូលទៅទូលសុំព្រះកែវនឹងស្ដេចកំពែង-ពេជ្រ ៗ ក៏ព្រមអនុញ្ញាតឲ្យនាំព្រះកែវទៅ ។ តមកស្រុកជៀងរ៉ាយកើតចម្បាំងនឹងស្រុកជៀងហៃ ៗ មានជ័យជំនះ ក៏កៀរគេមនុស្សទាំងពួងទៅទុកឯស្រុកជៀងហៃ ឯព្រះកែវមរកតក៏អារាធនាទៅជាមួយដែរ ហើយទ្រង់សាងប្រាសាទ ១ ថ្វាយព្រះកែវ ប្រដាប់ទៅដោយគ្រឿងកែវ, មាស, ប្រាក់ជាច្រើន ហើយធ្វើបុណ្យសម្ពោធ ៧ យប់ ៧ ថ្ងៃ ។ ព្រះពុទ្ធសាសនាក៏ចំរើនរុងរឿងណាស់ ដោយគេជះព្រះកែវមរកតនេះ តាំងអំពីព្រះកែវមកគង់នៅស្រុកជៀងហៃ ពុទ្ធសករាជកន្លងទៅបាន ២០០០ វស្សា ចុល្លសករាជ ៨១៨ ឆ្នាំ ព្រះកែវគង់នៅស្រុកជៀងហៃជាច្រើនជំនាន់ក្សត្រវៀន ៗ

មក ។ ចំណែកខាងក្រុងសតនាគនហុត (លាវហ្លួងព្រះបាង) មានក្សត្រ ១ អង្គព្រះនាមវិជុនរាជ មានព្រះរាជបុត្រព្រះនាមពោធិសាររាជកុមារ ។ មានព្រះជន្ម ១៥ វស្សាបិតាទិវង្គតទៅ ព្រះពោធិសារក៏ឡើងគ្រងរាជ-សម្បត្តិមានព្រះកេរ្តិ៍ល្បីល្បាញ ទើបស្តេចចៀងហ្មៃឲ្យនាំរាជធីតាឈ្មោះព្រះនាងយ៉តខាំមកថ្វាយជាមហេសី ។ ព្រះនាងប្រសូតព្រះរាជបុត្រ ១ អង្គព្រះនាមជ័យជេដ្ឋា ។ ឯក្សត្រស្រុកចៀងហ្មៃតមកមិនយូរប៉ុន្មានក៏ទិវង្គតទៅ គ្មានព្រះរាជបុត្រសន្តងរាជសម្បត្តិ ទើបសេនាមាត្យរាជបណ្ឌិតព្រមទាំងគណៈសង្ឃប្រជុំព្រមព្រៀងគ្នាថា ត្រូវទៅអញ្ជើញព្រះអង្គម្ចាស់ជ័យជេដ្ឋា រាជបុត្រប្បងរបស់ព្រះនាង យ៉តខាំ មកគ្រងរាជសម្បត្តិនៅស្រុកចៀងហ្មៃ ។ គ្រានោះ ព្រះជ័យជេដ្ឋាមានព្រះជន្មាយុត្រឹម ១២ វស្សាប៉ុណ្ណោះ តមកមិនយូរប៉ុន្មានព្រះពោធិសារក្សត្រក្រុងសតនាគនហុតក៏ទិវង្គតទៅ ព្រះជ័យជេដ្ឋាទ្រង់ជ្រាប ទើបទ្រង់ស្តេចត្រឡប់វិលទៅនគរសតនាគនហុតវិញ ហើយបាននាំយកព្រះកែវទៅផងហើយធ្វើបុណ្យសម្ពោធ ៧ យប់ ៧ ថ្ងៃ ។ ព្រះបាទជ័យជេដ្ឋាក៏បានគ្រងរាជ្យនៅក្រុងសតនាគនហុត ។ ឯក្រុងចៀងហ្មៃក៏ចាត់រើសរាជវង្សដទៃឡើងសោយរាជ្យតទៅ សេចក្តីនេះជ្រាបដល់ព្រះជ័យជេដ្ឋា ៗ ក៏ទ្រង់ក្រេវក្រោធ ទើបលើកទ័ពទៅវាយចៀងហ្មៃ ៗ ទប់ទល់ពុំបាន ក៏លើកស្រុកចៀងហ្មៃឲ្យទៅភូមា ៗ បញ្ជូនពលមកជួយជាចំនួនច្រើន ។ ព្រះជ័យជេដ្ឋាទ្រង់យល់ថានឹង

ច្បាំងតទល់កូមាពុំបាន ទើបត្រឡប់ថយទ័ពមកវិញ ហើយទ្រង់ត្រិះរិះថា ទីក្រុងសតនាគនហុតនេះជាទីច្រកតូចមានតែភ្នំដេរដាស មិនគួរជាទីតាំងក្រុងធំសោះ គួរតែទៅតាំងក្រុងនៅទីវាលធំស្រឡះ ទើបទ្រង់នាំគ្រួសារ អមាត្យរាជបរិពារ ព្រមទាំងព្រះកែវមរកតចុះមកតាំងក្រុងនៅវៀងចន្ទ ហើយទ្រង់សាងប្រាសាទ ១ ថ្វាយព្រះកែវក្នុងព្រះរាជវាំង ទ្រង់តាក់ខ្ញុំស្រី ១០០ នាក់ខ្ញុំប្រុស ១០០ នាក់ សម្រាប់ថែរក្សាព្រះកែវមរកត ដរាបដល់អស់ព្រះជន្មាយុរបស់ទ្រង់ ។

ចប់

# ពង្សាវតាររោម

(តមក)

ដែលសេសសល់នៅមកដល់វេលានេះជិត ២០០០ ឆ្នាំ តែមិនមានអ្នកប្រាជ្ញពង្សាវតារណាមើលយល់សេចក្ដីត្រឹម ១០-២០ ឆ្នាំក៏កម្រណាស់ ។ ជនពួកនេះខុសពីពួកក្រិកនិងពួកឡាតាំង ដោយមានរូបរាងទាបតឿជាត់ក្រអាញ កងកាយខ្លងវែង មុខប្រប៉ូញ ប្រមុះកោងក្ងក់ សក់ក្រញាញ់ ថ្ពាសទូលាយ ។ ពួកនេះមិនបានរៀបចំស្រុកទេសឲ្យបានចំរើនទេ ច្រើនតែចូលចិត្តខាងដាំដំណាំ និងធ្វើជំនួញតាមដើងទឹក ពួកនេះមានកេងសម្រាប់ធ្វើគ្រឿងលោហៈ គាបធ្វើរបស់ផ្សេងៗបានយ៉ាងផ្ចិតផ្ចង់មិនថាធ្វើដោយមាស ឬដែក ទង់ដែងទេ ។ ក្រៅពីនេះពួកនេះស្ទាត់ជំនាញក្នុងការប្រើទូក ប្រមូលយកជំនួញក្នុងផ្លូវសមុទ្រមេឌិតេរ៉ាណេមកតាន់ទុកនៅដៃខ្លួនជាចំនួនច្រើន បានធ្វើការលក់ដូរជាមួយនិងពួកគោល្វ", ពួកការថាស (Carthage) និងពួកក្រិក ។

នៅខាងត្បូងប្រទេសឥតាលី មានពួកក្រិកចូលមកអាស្រ័យនៅជាច្រើន ហើយបាននាំយកអារ្យធម៌និងរបបផែនការសិក្សារបៀបក្រិកចូលមកផ្សាយផង ហេតុនេះបានជាអារ្យធម៌របស់រោមនិងក្រិកមានលក្ខណៈប្រហែលៗគ្នាដោយច្រើន ។ អ្នកប្រាជ្ញទាំងឡាយច្រើនយល់ថាការរៀនប្រវត្តិសាស្ត្ររបស់ក្រិកនោះ ជារបស់ត្រូវរៀនមុនប្រវត្តិសាស្ត្ររបស់រោម ។

ក្នុងចំណោមពួកក្រិកនឹងពួកអេទ្រុស្ក៍ ជាពួកដែលមានសេចក្ដីចំរើនរុងរឿងមកហើយនោះ នៅមានប្រជាជន ១ ពួកទៀត នៅត្រង់កណ្ដាលប្រទេសឥតាលី ចិញ្ចឹមជីវិតដោយការចិញ្ចឹមសត្វនិងដាំដំណាំ ហៅថាពួកឡាតាំង បែងចែកគ្នានៅក្នុងភូមិលំនៅជា ២ ផ្នែកដោយឡែកពីគ្នា គឺ ១ ផ្នែកនៅតាមភ្នំ ១ ផ្នែកទៀតនៅទីទំនាប តាមដងទន្លេទីប្រ៍ ឬឡាស្យុម ឯពួកដែលនៅភ្នំនោះមិនមានការសេពគប់នឹងពួកដទៃទៀតទេ បានរក្សាប្រវេណីរបស់ខ្លួនពីបុរាណទុកមកជាយូរអង្វែង តែជាពួកជនទីទ័លក្រនឹងមានចិត្តសាហាវ ជាអ្នកចម្បាំងរឹងប៉ឹងក្លាហានហើយលើកពួកទៅប្លន់ជនពួកឯទៀតរឿយៗ តែមិនប្រាកដថាបានរួបរួមតាំងជាជាតិឡើងទេ ។ ឯពួកដែលនៅក្នុងទីទំនាបនោះខុសគ្នាឆ្ងាយ គឺមានការសេពគប់នឹងពួកក្រិកនឹងពួកអេទ្រុស្ក៍ សមាគមនឹងមនុស្សផ្សេងជាតិដទៃទៀត ទើបមានឱកាសទៅចម្លងយករបៀបដាំដំណាំ, របៀបកសាង, របៀបត្រួតត្រាស្រុកនឹងរបៀបសាសនា ។ ហេតុនេះហើយបានជាពួកនេះមានសេចក្ដីចំរើនឡើងយ៉ាងរួសរាន់ តាំងជាជាតិឡើងបាន ហៅថា ពួករ៉ូម៉ាំង (Romain) ។

ដើមដំបូង ជនពួកនេះបានបំបែកគ្នាត្រួតត្រាស្រុកមួយៗដោយឡែកៗពីគ្នា មិនបានរួបរួមគ្នាជារដ្ឋបាលមួយទេ កាលណាមានគ្រោះថ្នាក់កើតឡើងដល់ស្រុកទេស ដូចជាមានជនជាតិឯទៀតលើកទ័ពមក

ញាំញី ទើបរួមកំឡាំងគ្នាការពារសត្រូវ តែងធ្វើដូច្នេះរហូតមកដល់វេលាកសាងក្រុងរេមឡើងដោយពិតប្រាកដ ។

**អំពីដើមកំណើតនៃក្រុងរោម (Rome) —** នៅចំណែកទីទំនាបនៃប្រទេសឡាស្យ៉ូម មិនឆ្ងាយពីមាត់ពាមទន្លេទីប្រ៏ទេ ត្រង់កណ្ដាលទីទំនាបនេះមានបឹង ត្រពាំង ថ្លុកជាច្រើន មានទឹកទន្លេតែងជោរជន់ឡើងមកលិចជារឿយៗ នៅតំបន់នេះមានទួលតូចៗ ៧ ទួល ទួលដែលខ្ពស់ជាងគេហៅថា ប៉ាឡាតាំង (Palatin) កំពស់ ៥១ ម៉ែត្រ នៅលើទួលខ្ពស់នេះហើយមានវីរបុរសម្នាក់កើតឡើងឈ្មោះរេមុយលុស (Romulus) ជាអ្នកចាប់កសាងក្រុងរេមឡើង កាលពីថ្ងៃ ២១ អាវ្រីល មុន គ.ស. ៧៥៣ មុន ព.ស. ២១០ ។ ពាក្យថា រេមៗនេះមានអធិប្បាយជាពីរន័យ ន័យ ១ ថាមកពីឈ្មោះរេមុយលុសជាអ្នកតាំងបង្កើត ន័យ ១ ទៀតថាជាទីទួលខ្ពស់ ដ្បិតពាក្យថា រេមៗនេះប្រែតាមសព្ទក៏គឺទួលខ្ពស់ហ្នឹងឯង ។

ការកសាងនេះ មានពិធីចំឡែកប្លែកណាស់ មានសេចក្ដីដំណាលថា រេមុយលុសធ្វើតាមពិធីរបស់ពួកអេទ្រុស្ក៏ គឺដំបូងចាំឲ្យបានឫក្សពារពេលាល្អសិន វិធីរកឫក្សល្អនេះ មិនមែនគិតគូរតាមក្បួនលេខនព្វន្ដដូចពួកហោរទេ គឺរង់ចាំមើលផ្លូវសត្វស្លាបះហើរកាត់មក កាលបើឃើញសត្វហើរមកត្រូវផ្លូវដែលចាត់ជាមង្គលល្អហើយ រេមុយលុសទំងបក្ខពួករបស់ខ្លួនក៏រៀបធ្វើពិធីបរិសុទ្ធ គឺរត់កាត់គំនរភ្លើងដែលកំពុងឆេះប្រាលឆ្អៅ

ព្រោះគេប្រកាន់ថាភ្លើងជាគ្រឿងលាងជំរះមន្ទិលស្មោកគ្រោក (មិនប្រើទឹកទេ) ។ លុះធ្វើពិធីរួចហើយ ពេមុយលុសក៏ជីករណ្ដៅមួយ ហើយអ្នកដែលនៅជួបជុំក្នុងទីនោះក៏យកដុំដីដែលខ្លួននាំយកមកពីភូមិស្រុករបស់ខ្លួន បោះចោលទៅក្នុងរណ្ដៅនោះទៅ ត្រង់រណ្ដៅនេះហើយដែលគេបានសាងផ្ទះព្រះភូមិសម្រាប់ឲ្យថែរក្សាស្រុកដែលកសាងឡើងថ្មីនោះ ។ តអំពីនោះ ពេមុយលុសក៏តែងខ្លួនជាលោកសង្ឃ យកសំពត់ឃ្លុំក្បាល ហើយយកនង្គ័លភ្ជួរទឹមគោ ១ ទឹមៗនេះគោ ១ ជាគោញីសារ គោ ១ ទៀត ជាគោឈ្មោលសម្បុរសទាំងគូ ទីដីដែលនៅក្នុងវង្វង់ស្នាមភ្ជួរនេះ គេប្រ-កាន់ថាជាទីស័ក្ដិសិទ្ធិ ដើរកាត់ពុំបាន វៀរលែងតែត្រង់កន្លែងដែលចាប់លើកដងនង្គ័លម្ដងៗ ជាទីសំគាល់ជាទ្វារសំរាប់ចេញចូល ។ ការធ្វើពិធីនេះបានតាត់ធ្វើយ៉ាងម៉ឺងម៉ាត់ណាស់ ពេមុយលុសបានកាប់សម្លាប់ប្អូនរបស់ខ្លួនម្នាក់ទៅ ព្រោះហេតុតែប្អូនប្រុសនោះទៅដើរកាត់រំលងស្នាមភ្ជួរជាចំនងប្រមាទមើលងាយដល់ពិធីនោះ ។

ពួកពេម៉ាំង គឺពួកអ្នកស្រុកពេមនោះតាមធម្មតាច្រើនតែមានសក់ខ្មៅ ភ្នែកខ្មៅ រាងតាបទ្រនាប់ ចង្កាមូលលៀនចេញបន្តិច ។ ពួកនេះខំស្វាហាប់ធ្វើការងារណាស់ ទើបមានរូបរាងកាយខែងរ៉ែង បេះស្រឡាញ់ភូមិលំនៅ ធ្វើជាទាហានមានសេចក្ដីអត់ធ្មត់ល្អ មិនចូលចិត្តដើរសាត់គ្រាត់ជួបជនជាតិឯទៀត ច្រើនតែទាស់ទែងគ្នាអំពីរឿងទំដីទាល់តែកើតក្ដីឡើងក៏មាន បើជាហេតុទាស់ទែងធំក៏កើតទៅជាចម្បាំងឡើងក៏មាន ។ (មានត)

# អំពីសេចក្ដីចំរើននៃវិទ្យាសាស្ត្រ

( តមកនឹងចប់ )

ក្នុងវេលាមានចម្បាំង វិទ្យុជាគ្រឿងទទួលធ្វើនាទីជាតែកុងយន្តហោះ កប៉ាល់ចម្បាំង ទេះអណ្ដើក ទេះមីត្រៃយ៉េរ គ្រាប់បែកអាកាស សុទ្ធតែមិនចាំបាច់មានពាហនជាអ្នកបរ – ជាអ្នកបាញ់ទេ តែគ្រឿងអស់នេះអាចហោះទៅលើអាកាសច្បាំងតទល់គ្នា ឬបោលគ្រាប់បែកក្នុងទីចម្បាំងបានដោយងាយ ៗ ចំណែកខាងកប៉ាល់មុជទឹក ឬកប៉ាល់ចម្បាំងក៏អាចបើកចេញទៅច្បាំងតទល់គ្នាបានដោយអំណាចវិទ្យុ ទាំងមានក្រុមពាហនគ្រឿងយន្តជាអ្នកចេញទៅច្បាំងបានដូចជាមនុស្ស តោងបញ្ជាដោយអំណាចវិទ្យុដែរ ដែលជាវិធីការរបស់អគ្គិសនីនុ៎ះឯង ។

អគ្គិសនីនេះជារបស់មានគុណប្រយោជន៍ច្រើនលើសលន់គណនា ស្ទើរតែកិច្ចការទាំងអស់ក្នុងលោកសម្រេចដោយអគ្គិសនី ។ កាលណាកិច្ចការខាងអគ្គិសនីមានសេចក្ដីចំរើនកើនឡើងជាងវេលានេះ ទាំងមានដំឡៃថោកគួរសមហើយ ទាំងនាំឲ្យលោកនេះមានសេចក្ដីចំរើនកើនឡើងទៀតមិនខាន ។ អ្នកប្រាជ្ញវិទ្យាសាស្ត្រគិតរកវិធីប្រើអគ្គិសនីឲ្យមានប្រយោជន៍ដល់មនុស្សគ្រប់គ្នាក្នុងលោកនេះ ។

វិធីដែលពោលមកនេះ គឺគិតផ្លាស់កំឡាំងភ្លើងអគ្គិសនីដែលធ្លាប់រត់ទៅតាមខ្សែទឹកក្រុត ដែលមានតាមផ្លូវថ្នល់នឹងតាមផ្ទះ ដូចយើងមើល

ឃើញសព្វថ្ងៃនេះ ជាវិធីប្រើកំឡាំងវិទ្យុបញ្ជូនភ្លើងទៅតាមអាកាសវិញ មិនបាច់ប្រើខ្សែដូចសព្វថ្ងៃនេះ ជាការបន្ទាត់ច្រើនផង មិនល្អមើលផង ៗ ប្រសិនបើការប្រើចង្កៀងតាមអគ្គិសនីក្នុងផ្ទះ ឬតាមផ្លូវថ្នល់មិនបាច់ប្រើខ្សែតនេះ គិតសម្រេចឡើងបានដូចវិទ្យុ យើងមានសង្ឃឹមថា អគ្គិសនីនឹងនាំឲ្យបានសម្រេចប្រយោជន៍ កិច្ចការផ្សេងៗតទៅទៀតជាអនេក-ប្រការ ៗ

បណ្តាកិច្ចការគ្រប់យ៉ាងគ្រប់ប្រការក្នុងលោក សឹងបានសម្រេចដោយៈរៀបរយៈ ដោយស្នាដៃនឹងកំឡាំងសតិបញ្ញា-កំឡាំងសេចក្តីព្យាយាមរបស់អ្នកប្រាជ្ញវិទ្យាសាស្ត្រ ៗ កាលបុណ្យមហកម្មដ៏ឧឡារិករបស់លោកនៅក្រុងនៅវយ៉កនោះ អ្នកប្រាជ្ញវិទ្យាសាស្ត្របានគិតប្រឌិតរបស់ប្លែកៗទៅសំដែងជាច្រើនយ៉ាង តែរបស់ដែលចំឡែកនឹងសំខាន់ជាងគេនោះ គឺរូបដំបូង "រូបយន្តមនុស្ស" ដែលអាចនិយាយនឹងកម្រើកបាន ៣២ ប្រការ ៗ វត្ថុប្រឌិតទី ២ គឺ "ពន្លឺដែលចេះលេងភ្លេង" គេធ្វើជាសសរខ្ពស់មានអគ្គិសនីមានលេងភ្លេងគ្រប់ៗ ខណៈដែលពន្លឺនោះផ្លាស់ព័ណ៌ភ្លើង ៗ វត្ថុប្រឌិតទី ៣ គឺ "គ្រឿងកំដៅដោយវិទ្យុ" ជាជើង-ក្រានអគ្គិសនីបែបថ្មី ដែលគេប្រើវិទ្យុមកធ្វើឲ្យកើតកំដៅឡើង ៗ គ្រឿងប្រឌិតទី៤ គឺ "ការប្រើវិទ្យុឲ្យបើករថភ្លើង" ជារថភ្លើងដែលបើកទៅតាមផ្លូវដែកបានមិនបាច់មានអ្នកបររថទេ ប៉ុន្តែបើកទៅបានតាមបង្គាប់របស់វិទ្យុ ៗ

វត្ថុប្រឌិតទី ៥ គឺ "មេដែកដែលមានកំឡាំងច្រើនបំផុត" អាចធ្វើឲ្យផ្ទាំងដែកអណ្តែតឡើងទៅលើអាកាសបានយ៉ាងចំឡែក ។ វត្ថុប្រឌិតទី ៦ គឺ "គ្រឿងចក្រដួងព្រះអាទិត្យ" ដែលប្រើកំដៅដួងព្រះអាទិត្យ មកធ្វើឲ្យគ្រឿងម៉ាស៊ីនវិលបាន គេស្មានថាគ្រឿងម៉ាស៊ីននេះហើយដែលនឹងធ្វើប្រយោជន៍ឲ្យយ៉ាងធំក្រៃលែងដល់លោកទៅខាងមុខ ។

សម័យនេះ វិទ្យាសាស្ត្រកំពុងចំរើនទៅមុខយ៉ាងរួសរាន់ ទើបធ្វើឲ្យមនុស្សយើងមានគ្រឿងប្រើប្រាស់ជាច្រើនយ៉ាងស្មុកស្មះ ដូចជាក្រដាសដែលកើតឡើងដោយអំណាចវិទ្យាសាស្ត្រ ជារបស់មានប្រយោជន៍ដល់លោកយ៉ាងច្រើនប្រហែលនឹងដែកដែរ ព្រោះយើងយកក្រដាសមកប្រើធ្វើឲ្យលោកចំរើនឡើងជាច្រើន ព្រោះក្រដាសប្រើបានច្រើនផ្លូវ ដូចជាប្រើបោះពុម្ពសៀវភៅ ធ្វើក្រដាសប្រាក់ ខ្ចប់អីវ៉ាន់ ធ្វើជញ្ជាំង ធ្វើក្បឿង ធ្វើក្រដាសមិនឆេះភ្លើង ធ្វើស្បែកបូម ធ្វើក្រដាសតម្រង ។ល។ នៅទីបំផុត យើងយកក្រដាសប្រើជាគ្រាប់បែកក្នុងវេលាមានចម្បាំងទៀតផង ។

វិធីទុកនឹងរក្សាអាហារតាមផ្លូវវិទ្យាសាស្ត្រ នោះកាន់តែចំរើនឡើងទៀតជាច្រើន ដូចជាខណៈនេះ យើងមានទូសម្រាប់ទុកអាហារគោជនបានយូរមិនស្អុយខូចបាន ដោយគេបានដាស់កាសដែលមានគុណសម្បត្តិរក្សាអាហារមិនឲ្យស្អុយខូច ទូខ្លះនោះគេបានធ្វើពន្លឺស្នើម្យ៉ាងទុកខាង

ក្នុងជាគ្រឿងសម្លាប់ប៉័កតេរីក្នុងអាកាស ការពារអាហារនោះឲ្យកាន់តែល្អឡើងទៀត ។

ប្រទេសផ្សេងៗក្នុងទ្វីបអឺរ៉ុប និងអាមេរិក សឹងនាំគ្នាមកគិតគូរកែប្រែធ្វើរបស់ដែលឥតថ្លៃឲ្យទៅជារបស់មានដំឡៃគួរប្រើឡើង ដូចជាចំបើងដើមពោត, សំបកសណ្តែកដី, កំទេចឈើ, និងអាចម៍រណារជាដើមឲ្យមានប្រយោជន៍ឡើង ។ ការធ្វើក្រដាសក៏អាស្រ័យចំបើង និងកំណាត់ឈើកំទេចកំទីអាចម៍រណារ គេយកមកប្រើធ្វើជាស្ករហើយក្លាយទៅជាជំនួញមួយធំនៅស្រុកអាល្លឺម៉ង់ ទឹកគ្នាតទឹកអំពៅ ក្រៅពីប្រើទឹកធ្វើស្ករ គេប្រើកាកអំពៅនោះធ្វើជារបស់ស្វិតៗបានទៀត ដូចជាធ្វើប្រអប់សាប៊ូ ប្រអប់ម្សៅ ធ្វើខ្សែរ ធ្វើក្រដាសបានទៀត ។

រួមសេចក្តីថា អ្នកប្រាជ្ញវិទ្យាសាស្ត្រក្នុងសតវត្សរ៍ទី ២០ នៃគ្រិស្តសករាជនេះ មានគំនិតគិតគូរក្នុងការសាងលោកឲ្យបានចំរើនឡើងយ៉ាងបរិបូណ៌ ។ គេអាចគិតស្មានថា តទៅខាងមុខទៀត វិទ្យាសាស្ត្រនឹងមានសេចក្តីចំរើនជាងសព្វថ្ងៃនេះ មនុស្សយើងអាចមិនបាច់គោងធ្វើអ្វី ដោយមានគ្រឿងអគ្គិសនីធ្វើការជំនួសយើងគ្រប់ផ្លូវអស់ហើយ ហើយអាហារដែលយើងបរិភោគសោតទៀតក៏មិនបាច់បរិភោគជាចំនួនច្រើនដូចសព្វថ្ងៃនេះទេ នេះហើយជាផលនៃសេចក្តីចំរើនតាមផ្លូវវិទ្យាសាស្ត្រក្នុងសម័យបច្ចុប្បន្ននេះ ។

ខេមរង្សី